ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០០.ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ ហៅកាត់ថា **ក.គ.អ.អ.** ដែលមានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធាន
- ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន អនុប្រធានអចិន្ត្រៃយ៍
- ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន
- ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- ឯកឧត្តម **ស៊ូ ភិរិន្ទ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **តេង សាវឿង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **អ៊ូ សំអួន** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- ឯកឧត្តម **អ៊ឹម កុច** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- ឯកឧត្តម **ប៉ែន សុផល** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- ឯកឧត្តម **គន់ វ៉ាន់ថារ៉ា** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិក
- ឯកឧត្តម **តែ គុយសាំង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
- ឯកឧត្តម **នូ សុវត្ថិ** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
- ឯកឧត្តម **អ៊ុក សុជាតិ** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
- ឯកឧត្តម **ថិត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
- ឯកឧត្តម **ឌិត ទីណា** រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល សមាជិក
- ឯកឧត្តមនាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក
- ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឯកឧត្តម **ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា សមាជិក
- ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត សមាជិក
- ឯកឧត្តម **ហេង រតនា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា សមាជិក
- ឯកឧត្តម **កែវ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា សមាជិក
- ប្រធានលេខាធិការដ្ឋាន **ក.គ.អ.អ.** សមាជិក

**ប្រការ២.-**

**ក.គ.អ.អ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- បញ្ជ្រាបការយល់ដឹងនិងផ្សព្វផ្សាយសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ ដល់

- រៀបចំនិងធ្វើបច្ចុប្បន្នកម្មលើគោលនយោបាយនិងគម្រោងផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ពិនិត្យ វាយតម្លៃ និងលើកយោបល់សុំការសម្រេចជូនរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដើម្បីសម្រេចលើគម្រោងការអនុវត្តដោយសហគមន៍ឬអង្គការជាតិនិងអន្តរជាតិក្នុងសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- វាយតម្លៃនិងលើកយោបល់សុំការសម្រេចជូនរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដើម្បីទទួលស្គាល់សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ពិនិត្យនិងតាមដានរាល់ប្រតិបត្តិការគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- រៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់នានាដើម្បីគ្រប់គ្រងសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ផ្តល់ជំនួយបច្ចេកទេសចាំបាច់ដល់សហគមន៍និងប្រតិបត្តិករក្នុងសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ផ្តល់រង្វាន់ស្លាកសញ្ញាលើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ សហគមន៍ និងអ្នកវិនិយោគក្នុងគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ធ្វើការសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីសម្របសម្រួលការងារអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍កម្ពុជាឱ្យមានប្រសិទ្ធភាព
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**ប្រការ៣ .-**

សមាជិក **គ.គ.អ.អ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំប្រជុំ។

**ប្រការ៤ .-**

**គ.គ.អ.អ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជន ឱ្យចូលរួមប្រជុំពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

**ប្រការ៥ .-**

បែបបទនិងនីតិវិធីអនុវត្តការងាររបស់ **គ.គ.អ.អ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.គ.អ.អ.**។

**ប្រការ៦ .-**

ដើម្បីធានានូវប្រសិទ្ធភាពការងារក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន **គ.គ.អ.អ.** អាចបង្កើតក្រុមពិគ្រោះយោបល់សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍មួយ ដែលមានសមាសភាពដូចខាងក្រោម៖

- តំណាងសមាគមឧស្សាហកម្មទេសចរណ៍ ១ រូប
- តំណាងសាលាវិជ្ជាជីវៈទេសចរណ៍ ១ រូប
- តំណាងសមាគមធនាគារកម្ពុជា ១ រូប
- តំណាងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ១ រូប
- តំណាងសហគមន៍ដែលពាក់ព័ន្ធនានា មួយចំនួន
- តំណាងអង្គការជាតិ អន្តរជាតិ និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យអេកូទេសចរណ៍ មួយចំនួន

សមាសភាពជាក់ស្តែងរបស់ក្រុមពិគ្រោះយោបល់សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍របស់ **គ.ត.អ.អ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.អ.អ.**។

ក្រុមពិគ្រោះយោបល់សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍មានភារកិច្ចផ្តល់មតិយោបល់ផ្នែកបច្ចេកទេសដល់ **គ.ត.អ.អ.** និងជួយសម្រួលផ្តល់ឯកសារនិងផ្តល់កិច្ចសហការក្នុងដំណើរការការងាររបស់ **គ.ត.អ.អ.**។

**ប្រការ៧ ..**

**គ.ត.អ.អ.** មានលេខាធិការដ្ឋានមួយជាជំនួយការនៅទីស្តីការក្រសួងទេសចរណ៍។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ត.អ.អ.**។ សមាសភាពជាក់ស្តែងរបស់លេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**គ.ត.អ.អ.** បន្ទាប់ពីមានការឯកភាពពីអនុប្រធានទាំងពីរ។

**ប្រការ៨ ..**

**គ.ត.អ.អ.** មានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ នៅក្នុងកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

**ប្រការ៩ ..**

**គ.ត.អ.អ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិប្រចាំឆ្នាំស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ១០ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ